រាជរដ្ឋាភិបាលកម្ពុជា

សុន្ទរកថា

របស់ឯកឧត្តមនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្នុងឱកាសបើកសិក្ខាសាលាថ្នាក់ជាតិ
ស្តីពី
កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
គន្លឹះសំខាន់ដើម្បីគាំទ្រការអភិវឌ្ឍប្រកបដោយសមធម៌

ភ្នំពេញ, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩

ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ
អស់លោក លោកស្រី ជាទីគោរព!

ខ្ញុំមានសេចក្តីសោមនស្សរីករាយ និង កិត្តិយសជាអនេកកប្បការ ដោយបានមកចូលរួមថ្លែងសុន្ទរកថាគន្លឹះ សំរាប់ការបើកសិក្ខាសាលាថ្នាក់ជាតិស្តីពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដ៏មានសារៈសំខាន់នេះ ។ កម្មវិធីនេះ គឺជាឧបករណ៍ដ៏សំខាន់មួយ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលគួសបញ្ជាក់ពី ការប្តេជ្ញាចិត្តយ៉ាងមោះមុត ក្នុងការឈានទៅសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និង ប្រសិទ្ធភាព ។

នៅក្នុងដំណាក់កាលទីពីរនៃយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់ ដើម្បី សម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពយូរអង្វែង ដោយធានាឱ្យមាននូវការបែងចែកកាលា-នុវត្តភាព និង ផ្លែផ្កាទទួលបានពីកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ ។ ការពង្រឹងវិស័យកសិកម្ម ការអភិវឌ្ឍ ផ្នែកឯកជន និង ការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ គឺជាទិដ្ឋភាពដ៏សំខាន់នៃយុទ្ធសាស្ត្ររបស់យើង ។ ធាតុសំខាន់ៗផ្សេងទៀតរបស់យុទ្ធសាស្ត្រចតុកោណ គឺកិច្ចការពារ និង ការអភិវឌ្ឍធនធានមនុស្ស តាមរយៈ ការលើកកម្ពស់ និង ការផ្សព្វផ្សាយសេវាអប់រំ និង សុខភាព ព្រមទាំងការពង្រីកបណ្តាញសុវត្ថិភាពសង្គម ។

ទោះជារាជរដ្ឋាភិបាលសម្រេចបាននូវកំណើនសេដ្ឋកិច្ចដ៏គួរឱ្យកត់សម្គាល់ និង ការកាត់បន្ថយភាពក្រីក្រជាបន្តបន្ទាប់ ពី ៣៥ ភាគរយ ក្នុងឆ្នាំ ២០០៤ មកនៅត្រឹមតែប្រមាណជា ៣០ ភាគរយ ក្នុងឆ្នាំ ២០០៧ ក្តី ក៏គម្លាតរវាងអ្នកមាន និង អ្នកក្រ ជាពិសេសវិសមភាពរវាងទីប្រជុំជន និង ជនបទ នៅតែជាបញ្ហាប្រឈមមួយ សម្រាប់ប្រទេសកម្ពុជា ។ ក្នុងឆ្នាំ២០០៤ ចំនួន ៩១,៧ ភាគរយ នៃប្រជាពលរដ្ឋក្រីក្រ គឺរស់នៅតាមតំបន់ជនបទ។ ទោះបីជាកំណើនសេដ្ឋកិច្ចជាគន្លឹះសំខាន់ សម្រាប់ការអភិវឌ្ឍន៍ជាតិ និង ការលើកកម្ពស់វិបុលភាពរួមក៏ដោយ តែយើងពិនិត្យឃើញកាន់តែច្បាស់ថា កំណើនសេដ្ឋកិច្ចនេះ ពុំបានធានាដោយស្វ័យប្រវត្តិចំពោះប្រជាពលរដ្ឋនូវការទទួលផលប្រយោជន៍ទាំងអស់គ្នាឡើយ ។ ទន្ទឹមនឹងនេះ ធនធានរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីលុបបំបាត់ភាពក្រីក្រនៅមានកម្រិត ។ ដូច្នេះ ដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រឱ្យបានលឿន ជាការចាំបាច់ត្រូវតែមានការបែងចែកដោយផ្ទាល់នូវធនធានអភិវឌ្ឍន៍មួយចំនួន សម្រាប់ជួយដល់ប្រជាពលរដ្ឋក្រីក្រ និង ងាយរងគ្រោះបំផុត ។ ធ្វើបែបនេះ គឺដើម្បីបង្កើនសមត្ថភាពរបស់ប្រជាពលរដ្ឋក្រីក្រទាំងនោះ ឱ្យបំពេញនូវតម្រូវការជាមូលដ្ឋានរបស់ពួកគាត់ លើកកម្ពស់ជីវភាពរស់នៅ អភិវឌ្ឍធនធានមនុស្ស និង ការពារពួកគាត់ ពីវិបត្តិដែលអាចបណ្តាលឱ្យធ្លាក់ទៅក្នុងភាពក្រីក្រ ឬ ធ្វើឱ្យស្ថានភាពលំបាករបស់ពួកគាត់កាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ ។ ដូច្នេះ តាមរយៈអន្តរាគមន៍បែបនេះ យើងនឹងចូលរួមចំណែកលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស សក្តានុពលភាពសេដ្ឋកិច្ច និង ស្ថិរភាពទាំងផ្នែកសង្គម និង នយោបាយ ។

ហេតុផលមួយទៀត ដែលធ្វើឱ្យគម្លាតរវាងអ្នកមាន និង អ្នកក្រ នៅតែជាបញ្ហាប្រឈមដ៏ចម្បង សម្រាប់រាជរដ្ឋាភិបាលនិង ដៃគូអភិវឌ្ឍន៍ គឺថា រហូតមកទល់ពេលថ្មីៗនេះ យើងនៅខ្វះខាតយន្តការដែលមានស្តង់ដារត្រឹមត្រូវនិងអាចជឿជាក់បាន ដើម្បីបែងចែកសេវា និង ជំនួយ ជូនដល់ប្រជាពលរដ្ឋក្រីក្រ និង ងាយរងគ្រោះបំផុត ។ អ្នកផ្តល់សេវាជាស្ថាប័នរដ្ឋ និង អង្គការមិនមែនរដ្ឋាភិបាលជាច្រើន បាននិងកំពុងកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រដោយឡែកៗពីគ្នា ដោយគ្មានការសម្របសម្រួល ហើយទិន្នន័យទទួលបានពុំត្រូវបានចែករំលែករវាងស្ថាប័ន និង អង្គការទាំងនោះឡើយ ។ រាជរដ្ឋាភិបាល ផ្តល់អាទិភាពខ្ពស់បំផុតដល់សុខដុមនីយកម្មនៃនីតិវិធីនានា សម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ក្នុងគោលបំណងកាត់បន្ថយការចំណាយទូទៅ សំរាប់ការជ្រើសរើសក្រុមគោលដៅ និង ការប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពនូវធនធានអភិវឌ្ឍន៍ដែលមានកម្រិត ។ បច្ចុប្បន្ននេះ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ផ្តល់ឱ្យយើងនូវឧបករណ៍ដ៏មានប្រសិទ្ធភាពមួយ សម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅតាមតំបន់ជនបទ ។

ដូច្នេះ ឆ្លៀតឱកាសនេះ ខ្ញុំសូមសម្តែងនូវអំណរសរសើរដល់ក្រសួងផែនការ ចំពោះការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងក្នុងអំឡុងពេល ៣ ឆ្នាំកន្លងមក ក្នុងការរៀបចំសាកល្បង និង កែលំអនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និង លក្ខណៈវិនិច្ឆ័យស្តង់ដាររួម សម្រាប់កំណត់គ្រួសារក្រីក្រ និង ចំណាត់ថ្នាក់ភាពក្រីក្ររបស់គ្រួសារទាំងនោះ ។ ខ្ញុំក៏សូមសម្តែងនូវការកោតសរសើរផងដែរ ចំពោះកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ រវាងក្រសួងផែនការ និង ក្រសួងមហាផ្ទៃ ក្នុងការអនុវត្តនីតិវិធីនៅថ្នាក់មូលដ្ឋាន ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !

ក្នុងឆ្នាំ ២០០៧ និង ២០០៨ ក្រសួងផែនការបានអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្នុងភូមិចំនួនប្រហែល ២១០៩ ភូមិ នៅក្នុងខេត្ត ៥ ។ រហូតមកដល់ត្រឹមពាក់កណ្តាលឆ្នាំ ២០០៩ ក្រសួងផែនការនឹងអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងភូមិចំនួនប្រហែល ២៨៧៦ ក្នុងខេត្ត ៥ បន្ថែមទៀត ។ មានន័យថា សរុបទាំងអស់មានចំនួនជាង ៥000 ភូមិ គឺច្រើនជាងមួយភាគបីនៃភូមិទាំងអស់ក្នុងប្រទេសកម្ពុជា ។ អង្គការដែគូ ដែលកំពុងធ្វើការលើវិស័យសុខាភិបាល ក៏បានអនុវត្តនីតិវិធីស្តង់ដារក្នុងភូមិចំនួន ១៣២២ ក្នុងខេត្តផ្សេងៗទៀតផងដែរ ហើយក្នុងឆ្នាំ ២០០៩ អង្គការដែគូទាំងនោះ នឹងធ្វើការនៅតាមភូមិរាប់រយបន្ថែមទៀត ។ នេះបង្ហាញឱ្យឃើញថា ត្រឹមចុងឆ្នាំ២០០៩នេះ ជាងពាក់កណ្តាលនៃភូមិ នៅតាមតំបន់ជនបទនឹងត្រូវបានគ្របដណ្តប់ដោយកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។ ទិន្នន័យទាំងនេះ នឹងត្រូវយកទៅបញ្ចូលក្នុងទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រថ្នាក់ជាតិ សម្រាប់ចែករំលែកដល់អ្នកផ្តល់សេវាជាស្ថាប័នរដ្ឋ និង អង្គការមិនមែនរដ្ឋាភិបាលនានា ។ ក្រសួងផែនការ បានផ្សព្វផ្សាយទិន្នន័យទាំងនោះ ដល់អ្នកផ្តល់សេវាដែលកំពុងធ្វើប្រតិបត្តិការ នៅថ្នាក់ខេត្តក្នុងខេត្តចំនួន ៥ រួចរាល់ហើយ កាលពីឆ្នាំ ២០០៧ និង ២០០៨ កន្លងមក និងនៅនាទីចុងក្រោយនៃសិក្ខាសាលានេះ ទិន្នន័យទាំងនេះ នឹងត្រូវចែកចាយដល់អ្នកចូលរួមទាំងអស់ ។

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រថ្នាក់ជាតិ បានបង្ហាញយ៉ាងច្បាស់ថា រាជរដ្ឋាភិបាលបានប្រើប្រាស់រចនាសម្ព័ន្ធវិមជ្ឈការមានស្រាប់ និង បានដំណើរការ ដោយមានការចូលរួមពីតំណាងឃុំ និង ភូមិ ក្នុងការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រឱ្យមានប្រសិទ្ធភាព ។ នៅពាក់កណ្តាលឆ្នាំនេះ ការស្ទង់មតិមួយទៅលើអ្នកអនុវត្ត និង ភាគីពាក់ព័ន្ធនៅថ្នាក់ខេត្ត ឃុំ និង ភូមិ បានបង្ហាញពីការគាំទ្រយ៉ាងខ្លាំងដល់កម្មវិធីនេះ និង បង្ហាញពីភាពជឿជាក់ខ្ពស់លើសុក្រិតភាព និង ភាពមិនលំអៀង នៃលទ្ធផលដែលទទួលបានពីការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។ ដូច្នេះ យើងមានមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការពង្រីកកម្មវិធីនេះឱ្យដល់តំបន់ជនបទទាំងអស់នៅទូទាំងប្រទេស ។

ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំសូមគូសបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាល ចំពោះការពង្រីកកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះ ឱ្យគ្របដណ្តប់តំបន់ជនបទទូទាំងប្រទេស ហើយខ្ញុំនឹងខិតខំរកធនធានហិរញ្ញវត្ថុ ដើម្បីវិភាជន៍ថវិកាជាតិប្រចាំឆ្នាំឱ្យមានចំនួនកើនឡើង ចាប់ពីឆ្នាំ ២០១០ ទៅ សម្រាប់គាំទ្រដល់កម្មវិធីនេះ ។ ដោយសារតែថវិកាជាតិនៅមានកម្រិត ខ្ញុំក៏សូមទទួចឱ្យដែគូអភិវឌ្ឍន៍ជួយផ្តល់ហិរញ្ញវត្ថុដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាបញ្ហាអាទិភាព ។ ដូច្នេះ ខ្ញុំសុំស្នើក្រសួងផែនការរៀបចំផែនការមេមួយនៅដើមឆ្នាំ ២០០៩ នេះ ដើម្បីបាន់ស្មានការចំណាយសម្រាប់ពង្រីកការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រទូទាំងប្រទេស សម្រាប់ការពិចារណាក្នុងក្របខ័ណ្ឌថវិកាជាតិនិងដាក់ជូនដែគូអភិវឌ្ឍន៍ដើម្បីសុំការគាំទ្រ។

សំរាប់ជំហ៊ានបន្ទាប់ ខ្ញុំយល់ឃើញថា យើងត្រូវគ្រោងផែនការ ដើម្បីសម្រេចការកំណត់អត្តសញ្ញាណកម្ម គ្រួសារក្រីក្រឱ្យបានពាក់កណ្តាលនៃផ្ទៃប្រទេស ត្រឹមឆ្នាំ ២០១០ ហើយពាក់កណ្តាលទៀតនឹងត្រូវធ្វើនៅឆ្នាំ ២០១១ បន្ទាប់ពីនោះ គឺការធ្វើបច្ចុប្បន្នភាពអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងតំបន់នីមួយៗ រៀងរាល់ពីរឆ្នាំម្តង និងជាបន្តបន្ទាប់ ។

ក្នុងឆ្នាំ ២០០៧ និង ២០០៨ ក្រសួងផែនការ និង អង្គការដៃគូជាប្រតិបត្តិករមូលនិធិសមធម៌សុខភាព បានដំណើរការយ៉ាងល្អ ក្នុងការពង្រីកការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដោយប្រើប្រាស់នីតិវិធីស្តង់ដារ ទៅដល់តំបន់ជាច្រើន ដោយបែងចែកការទទួលខុសត្រូវលើតំបន់ខុសៗគ្នា ។ ទោះជាយ៉ាងនេះក្តី បញ្ហាកង្វះខាតថវិកា និង អាទិភាពប្រតិបត្តិការ បណ្តាលឱ្យការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវធ្វើឡើងក្នុងខេត្ត និងស្រុកខុសៗគ្នា ក្នុងពេលផ្សេងៗគ្នា ហើយអាចធ្វើបានលើខេត្តទាំងមូលតែមួយចំនួនប៉ុណ្ណោះ ។ ការអនុវត្ត ការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រដោយអង្គការផ្សេងៗគ្នា ក្នុងតំបន់តូចៗ ត្រូវការចំណាយខ្ពស់ទៅលើការគ្រប់គ្រង និង ការសម្របសម្រួល ។ ជាការពិត ទិន្នន័យដែលប្រមូលបានក្នុងពេលខុសៗគ្នា ក្នុងតំបន់ផ្សេងៗគ្នា ធ្វើឱ្យមានការលំបាកដល់ការប្រៀបធៀបលទ្ធផលនៃការធ្វើអត្តសញ្ញាណកម្មនេះ ។ លើសពីនេះ កង្វះធនធានពីអង្គការដៃគូ បង្កឱ្យមានការយឺតយ៉ាវដល់ការបញ្ចូលទិន្នន័យ ជាហេតុធ្វើឱ្យមានការលំបាកដល់ការប្រមូលផ្តុំទិន្នន័យនៅក្នុងទិន្នន័យមូលដ្ឋានថ្នាក់ជាតិឱ្យបានទាន់ពេលវេលា ដើម្បីចែកចាយទិន្នន័យទាំងនោះដល់អ្នកផ្តល់សេវាផ្សេងៗទៀត ។

ប្រសិនជាមានការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាប្រព័ន្ធនៅទូទាំងប្រទេស ដោយក្រសួងផែនការ វាអាចផ្តល់ផលប្រយោជន៍ជាច្រើន ។ ដោយសារក្រសួងផែនការប្រើប្រាស់រចនាសម្ព័ន្ធវិមជ្ឈការ សម្រាប់ការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ សមត្ថភាពរបស់រដ្ឋមានការអភិវឌ្ឍជាបន្តបន្ទាប់ក្នុងការសម្របសម្រួលចាត់ចែង និង អនុវត្តដំណើរការនេះ ដែលជាកត្តាមួយលើកកម្ពស់និរន្តរភាព ។ ការគ្រប់គ្រង និង ការសម្របសម្រួលរបស់ក្រសួងផែនការតែមួយ នឹងនាំឱ្យមានការជ្រើសរើសតំបន់និងកំណត់ពេលវេលា សម្រាប់ការអនុវត្តការងារជាលក្ខណៈប្រព័ន្ធ ដែលនឹងធ្វើឱ្យមានលំនឹងសម្រាប់អ្នកអនុវត្តការងារ ។ ការធ្វើដូច្នេះនឹងធ្វើឱ្យមានភាពងាយស្រួលក្នុងការសម្របសម្រួលការបញ្ចូល និង ចែកចាយទិន្នន័យឱ្យទៀងពេលវេលា ដែលនឹងជួយអ្នកសម្រេចចិត្ត និង អ្នកផ្តល់សេវានានាក្នុងការរៀបចំផែនការសកម្មភាពរបស់ខ្លួន ។ ម្យ៉ាងវិញទៀត ដោយសារក្រសួងផែនការធ្វើការចែកចាយទិន្នន័យទូលំទូលាយ ផលប្រយោជន៍ដែលទទួលបានធៀបនឹងការចំណាយ នឹងមានភាពប្រសើរជាងមុន ។

ខ្ញុំសូមផ្តល់យោបល់ខ្លះៗ អំពីការចំណាយលើការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមនីតិវិធីថ្នាក់ជាតិ ។ ជាការពិត ការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ ត្រូវចំណាយច្រើនជាងការអនុវត្តរបស់អង្គការមិនមែនរដ្ឋាភិបាល គិតក្នុងមួយគ្រួសារៗ ។ ប៉ុន្តែ នេះគឺដោយសារការប្តេជ្ញចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការប្រើប្រាស់រចនាសម្ព័ន្ធវិមជ្ឈការ ក្នុងការអនុវត្តដែលមានចំនួនមនុស្សពាក់ព័ន្ធ

ក្នុងការគ្រប់គ្រង និង សម្របសម្រួលច្រើនជាង និង តម្រូវឱ្យមានការបណ្តុះបណ្តាលបន្ថែម ។ ម្យ៉ាងវិញទៀត ក្រសួងផែនការអនុវត្តនីតិវិធីនេះព្រមៗគ្នានៅគ្រប់តំបន់ រីឯអង្គការមិនមែនរដ្ឋាភិបាល អនុវត្តដំណើរការនេះ តាមលក្ខណៈវិកិល ។ ដូច្នេះក្រសួងផែនការ មានលទ្ធភាពប្រមូលទិន្នន័យបានឆាប់រហ័ស ហើយទិន្នន័យទទួលបានអាចយកមកប្រៀបធៀបគ្នាកាន់តែប្រសើរ ពីព្រោះទិន្នន័យទាំងនោះឆ្លុះបញ្ចាំងពីស្ថានភាពក្រីក្ររបស់គ្រួសារនីមួយៗក្នុងពេលតែមួយ ។ ដំណើរការរបស់ក្រសួងផែនការ រួមបញ្ចូលទាំងការផ្សព្វផ្សាយព័ត៌មាន និងចែកចាយទិន្នន័យនៅថ្នាក់ខេត្ត និង ថ្នាក់ស្រុក ដែលជំរុញឱ្យមានការប្រើប្រាស់ទិន្នន័យយ៉ាងទូលំទូលាយ ។

ឆ្នាំ ២០០៨ គឺជាឆ្នាំដំបូងដែលទិន្នន័យស្តីពីគ្រួសារក្រីក្រ មានសម្រាប់ខេត្តមួយចំនួន ក្នុងពេលតែមួយ ហើយថ្ងៃនេះ គឺជាថ្ងៃដំបូងដែលរាជរដ្ឋាភិបាលកំពុងផ្សព្វផ្សាយទិន្នន័យឆ្នាំ ២០០៨ នៅថ្នាក់ជាតិ ។ អាស្រ័យហេតុនេះ ខ្ញុំសូមអំពាវនាវដល់ក្រសួងមួយចំនួនដែលជាប្រតិបត្តិករផ្តល់សេវា ឬ ជំនួយដល់គ្រួសារក្រីក្រផ្ទាល់ ហើយមានកម្មវិធី ឬ សកម្មភាពណាដែលអនុវត្តនៅក្នុងតំបន់ ដែលគ្របដណ្តប់ដោយកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ សូមមេត្តាចាប់ផ្តើមប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រសម្រាប់ធ្វើជាមូលដ្ឋាន ក្នុងការជ្រើសរើសតំបន់ និងគ្រួសារគោលដៅ សម្រាប់ផ្តល់សេវាឬជំនួយនោះ ។ សូមរដ្ឋមន្ត្រីក្រសួង ពាក់ព័ន្ធទាំងអស់ ជម្រាបជូនដល់ស្ថាប័នក្រោមសមត្ថកិច្ចរបស់ខ្លួនអំពីសំណូមពរនេះ ។

នាពេលបច្ចុប្បន្ននេះ ក្រសួងផែនការកំពុងរៀបចំសេចក្តីព្រាងអនុក្រិត្យមួយដោយគូសបញ្ជាក់ពីគោលនយោបាយរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធទៅនឹងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ទាក់ទងនឹងបញ្ហានេះ ខ្ញុំសុំធ្វើសំណូមពរមួយចំនួនទាក់ទងទៅនឹងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការប្រើប្រាស់ទិន្នន័យស្តីពីគ្រួសារក្រីក្រ។

ក្នុងពេលជាមួយគ្នានេះដែរ ខ្ញុំក៏សូមសំណូមពរឱ្យដៃគូអភិវឌ្ឍន៍ និង អង្គការមិនមែនរដ្ឋាភិបាល ប្រើប្រាស់ទិន្នន័យ ដែលបានមកពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ សម្រាប់កំណត់គ្រួសារគោលដៅ ដើម្បីផ្តល់សេវា ឬ ជំនួយដល់ពួកគេ នៅក្នុងតំបន់ណាដែលមានទិន្នន័យគ្រួសារក្រីក្រ ។ សូមកុំប្រើប្រាស់វិធីសាស្ត្រផ្ទាល់ខ្លួន ដើម្បីកំណត់តំបន់ និង គ្រួសារគោលដៅរបស់អស់លោក ប្រសិនបើក្រសួងផែនការ ឬ អង្គការដៃគូបាននិងកំពុងអនុវត្តនីតិវិធីស្តង់ដារថ្នាក់ជាតិក្នុងតំបន់ដូចគ្នានោះហើយ ។ សម្រាប់តំបន់ទាំងនេះ រាជរដ្ឋាភិបាលនឹងទទួលស្គាល់ជាផ្លូវការតែនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការតែប៉ុណ្ណោះ ។

នៅតំបន់ដែលក្រសួងផែនការ ឬអង្គការដៃគូរបស់ខ្លួនមិនទាន់បានអនុវត្ត ឬ មិនទាន់មានផែនការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងពេលឆាប់ៗនេះដោយការប្រើប្រាស់នីតិវិធីថ្នាក់ជាតិទេ អង្គការនានា ដែលមានបំណងចង់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ គួរធ្វើសុខដុមនីយកម្មនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ខ្លួនឱ្យស្របតាម *សេចក្តីណែនាំដល់ស្ថាប័ន និង អង្គការដៃគូ ដើម្បីអនុវត្តនីតិវិធីរួមមួយ សម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅតំបន់ជនបទ* ប្រសិនបើអាចអនុវត្តបាន ។ នីតិវិធីកែសម្រួលទាំងនោះ គួររៀបចំធ្វើឡើង ដោយមានការពិគ្រោះយោបល់ និង ទទួលបានការអនុម័តពីក្រសួងផែនការ ។

ក្នុងពេលដែលកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រគ្របដណ្ដប់ជាប្រព័ន្ធពេញផ្ទៃប្រទេស ស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និង អង្គការមិនមែនរដ្ឋាភិបាល គួរបញ្ឈប់ការប្រើប្រាស់នីតិវិធីផ្សេងៗទៀត សម្រាប់កំណត់អត្ត-សញ្ញាណគ្រួសារក្រីក្រ ។ ទោះជាយ៉ាងនេះក្តី ក្នុងករណីជាក់លាក់មួយចំនួន អាចមានតម្រូវការប្រើប្រាស់លក្ខណៈវិនិច្ឆ័យជាក់លាក់បន្ថែមមួយចំនួនទៀត សម្រាប់ជ្រើសរើសគ្រួសារចេញពីគ្រួសារក្រីក្រ ដែលបានធ្វើអត្តសញ្ញាណកម្មរួច (ឧទាហរណ៍ គ្រួសារគ្មានដីធ្លី គ្រួសារជនពិការ ឬ គ្រួសារ ដែលមានជំងឺរ៉ាំរ៉ៃ គ្រួសារគ្មានសត្វពាហនៈ។ល។)

ក្នុងអំឡុងកិច្ចប្រជុំវេទិកាកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កម្ពុជាឆ្នាំ ២០០៨ រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ បានពិភាក្សាអំពីគំនិតនៃការពង្រឹងបណ្ដាញសុវត្ថិភាពសង្គម ដែលមានលក្ខណៈជាប្រព័ន្ធ និង ការសម្រុះសម្រួលរួមដោយផ្តោតការយកចិត្តទុកដាក់ទៅលើគ្រួសារក្រីក្រ និង គ្រួសារងាយរងគ្រោះបំផុត ។ នាពេលបច្ចុប្បន្ននេះ កម្មវិធីបណ្ដាញសុវត្ថិភាពនានារបស់រាជរដ្ឋាភិបាល ផ្តោតទៅលើមន្ត្រីរាជការ អតីតយុទ្ធជន ជនពិការ និង ក្រុមគ្រួសាររបស់ពួកគាត់ ព្រមទាំងនិយោជិកក្នុងវិស័យការងារផ្លូវការ ហើយកម្មវិធីទាំងនេះ ស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នផ្សេងៗគ្នា ។ មនុស្សដែលកំពុងធ្វើការនៅក្នុងវិស័យការងារមិនផ្លូវការមិនរាប់បញ្ចូលទៅក្នុងនេះទេ ។ កម្មវិធីបណ្ដាញសុវត្ថិភាពសង្គមនាពេលបច្ចុប្បន្ននៅមានកម្រិតនៅឡើយ។ រាជរដ្ឋាភិបាលទទួលស្គាល់អំពីតម្រូវការក្នុងការកែលម្អបណ្ដាញសុវត្ថិភាពសង្គម ហើយក្នុងពេលឆាប់ៗខាងមុខនេះ ដោយសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាលនឹងចាប់ផ្តើមស្រាវជ្រាវ ពិនិត្យសកម្មភាពបណ្ដាញសុវត្ថិភាពសង្គម ដែលមានស្រាប់និងស្វែងរកគោលការណ៍ ដើម្បីរៀបចំយុទ្ធសាស្ត្របណ្ដាញសុវត្ថិភាពសង្គម ។ នៅប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនដែលមានកម្មវិធីបណ្ដាញសុវត្ថិភាពសង្គមថ្នាក់ជាតិ ហើយពួកគេប្រើប្រាស់ប្រភពទិន្នន័យរួម ស្តីពីគ្រួសារក្រីក្រដើម្បីកំណត់ក្រុមគោលដៅតាមគ្រប់ផ្នែកវិស័យរបស់កម្មវិធី ។ នៅប្រទេសកម្ពុជា ទិន្នន័យទទួលបានពីការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ អាចប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់កំណត់អ្នកទទួលផលប្រយោជន៍ ។

ជាទីបញ្ចប់ ខ្ញុំសូមបញ្ជាក់ពីការគាំទ្ររបស់រាជរដ្ឋាភិបាល ចំពោះកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។ រាជរដ្ឋាភិបាល នឹងគាំទ្រមូលនិធិ តាមរយៈការផ្តល់ហិរញ្ញប្បទាន និង សូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ឱ្យចូលរួមដើម្បីពង្រីកកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រឱ្យគ្របដណ្ដប់ទូទាំងប្រទេស និង មានការធ្វើបច្ចុប្បន្នភាព ជាប្រចាំ ។ កម្មវិធីនេះ គឺជាឧបករណ៍ ដ៏មានសារៈសំខាន់មួយដើម្បីជួយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និង អង្គការមិនមែនរដ្ឋាភិបាលក្នុងការប្រើធនធានឱ្យមានប្រសិទ្ធភាព និង ដោយមានការសម្របសម្រួលគ្នា ដើម្បីផ្តល់សេវា និង ជំនួយដល់ប្រជាជនក្រីក្រ និង ងាយរងគ្រោះបំផុត ។

សូមអរគុណ